# អង្គការផ្លែនអន្តរជាតិកម្ពុជា

## ឯកសារដេញថ្លៃ

# គម្រោងសាងសង់ឧបករណ៍លាងសម្អាតដៃ
# ដោយជើងនៅតាមសាលារៀន




សហការជាមួយ

ក្រសួងអប់រំ យុវជន និងកីឡា

ខែ កុម្ភៈ ឆ្នាំ ២០២២

# មាតិកា


ផ្នែកទី ១ ៖ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ

ផ្នែកទី ២ ៖ សេចក្តីណែនាំចំពោះអ្នកចូលរួមដេញថ្លៃ

ផ្នែកទី ៣ ៖ ការប្រកាសទទួលស្គាល់អ្នកម៉ៅការរបស់ភាគីម្ចាស់គម្រោង (ទម្រង់ឯកសារដេញថ្លៃ)

ផ្នែកទី ៤ ៖ ទម្រង់បែបបទព័ត៌មានអំពីគុណសម្បត្តិរបស់ក្រុមហ៊ុន ដោយមានភ្ជាប់មកជាមួយនូវវិញ្ញាបនប័ត្រក្រុមហ៊ុន

ផ្នែកទី ៥ ៖ បទដ្ឋានបច្ចេកទេស និងសេចក្តីលំអិតអំពីសម្ភារៈសាងសង់

ផ្នែកទី ៦ ៖ បញ្ជីប៉ាន់តម្លៃសាងសង់ឧបករណ៍លាងសម្អាតដៃដោយជើង

ផ្នែកទី ៧ ៖ គំនូរប្លង់ ឧបករណ៍លាងសម្អាតដៃដោយជើង

## ផ្នែកទី ១ ៖
## សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ

អង្គការផ្លែនអន្តរជាតិកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងស្តីពីការដេញថ្លៃគម្រោងសាងសង់ ឧបករណ៍លាងសម្អាតដៃដោយជើង ចំនួន១៨០ ដែលនឹងត្រូវប្រគល់ និងតំឡើងនៅតាមសាលារៀន ចំនួន៩០ សាលារៀន នៅក្នុងស្រុកចំនួន០៤ ក្នុងខេត្តព្រះសីហនុ ដូចក្នុងតារាងខាងក្រោម ៖

| ល.រ | ឈ្មោះស្រុក | សាលារៀន | ចំនួនឧបករណ៍លាងសម្អាតដៃដោយជើង |
|---|---|---|---|
| ១ | ក្រុងព្រះសីហនុ | ១៨ | ៣៦ |
| ២ | ស្រុកព្រៃនប់ | ៤២ | ៨៤ |
| ៣ | ស្រុកស្ទឹងហាវ | ១០ | ២០ |
| ៤ | ស្រុកកំពង់សិលា | ២០ | ៤០ |
| **សរុប** | | **៩០** | **១៨០** |

អង្គការផ្លែនអន្តរជាតិកម្ពុជា សូមអញ្ជើញស្ថាប័ន ក្រុមហ៊ុន អ្នកម៉ៅការ ឬ សិប្បកម្ម ទាំងអស់ដែលមានចំណាប់អារម្មណ៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចូលរួមដេញថ្លៃដោយបំពេញនូវឯកសារដេញថ្លៃដូចមានភ្ជាប់ និងបញ្ជាក់នៅក្នុងផ្នែកនីមួយៗ ដូចខាងក្រោម។

**ឯកសារតម្រូវដែលត្រូវភ្ជាប់មកជាមួយ ឯកសារដេញថ្លៃមានដូចខាងក្រោម ៖**

- ត្រូវមានវិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬជាមួយក្រសួងពាក់ពន្ធ័ (សម្រាប់ក្រុមហ៊ុន)។
- ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការម៉ៅការរបស់សាលាក្រុង ឬខេត្ត និងនៅមានសុពលភាព។
- ត្រូវមានប័ណ្ណប៉ាតង់សម្រាប់ឆ្នាំ២០២១ និង ឆ្នាំ២០២២ (ប្រសិនបើមាន) (សម្រាប់ក្រុមហ៊ុន)។
- ត្រូវមានបទពិសោធន៍យ៉ាងតិច០១ឆ្នាំ ក្នុងការផលិតគ្រឿងដែក ហើយត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាដែលក្រុមហ៊ុនបានធ្វើជាមួយអង្គការ ឬស្ថាប័នទាំងនោះដោយត្រូវភ្ជាប់មកជាមួយនូវរូបថតពណ៌ បង្ហាញពីស្នាដៃការងារនៃកិច្ចសន្យានោះ។
- ត្រូវមានអ្នកធានាយ៉ាងតិច០២នាក់ (ដោយប្រាប់ពីឈ្មោះ ទីកន្លែងធ្វើការ មុខងារ និងលេខទូរស័ព្ទទំនាក់ទំនង)។

**ពត័មានសំខាន់ៗអំពីការដេញថ្លៃ ៖**

- អ្នកដេញថ្លៃត្រូវស្រង់អត្រាឯកតា និងតម្លៃ គិតជាដុល្លារអាមេរិក។
- ឯកសារដេញថ្លៃ នឹងមានសុពលភាពរយៈពេល ៦០ថ្ងៃ។
- ការសាងសង់ត្រូវបញ្ចប់ក្នុងរយៈពេល៤៥ថ្ងៃយ៉ាងយូរ (ត្រឹមខែមេសា ឆ្នាំ២០២២)។ អ្នកម៉ៅការត្រូវធានារយៈពេលចំនួន០១ខែ ក្រោយពេលតំឡើងរួច។

- អ្នកម៉ៅការត្រូវដឹក ឧបករណ៍លាងសម្អាតដៃដោយជើងទាំងអស់ដែលបានផលិតរួច និងតំឡើង នៅតាមតំបន់គោលដៅ និងទីតាំងនីមួយៗ ទៅតាមចំនួនដែលបានកំណត់នៅក្នុងតារាងខាងលើ។
- អង្គការភ្លែននឹងធ្វើការទូទាត់ប្រាក់លើកទី១ចំនួន២០% នៃចំនួនទឹកប្រាក់សរុបក្រោយចុះកិច្ចសន្យាសាងសង់ជាមួយអ្នកម៉ៅការ និងក្រោយពេលអ្នកម៉ៅការបានដឹកសម្ភារៈសាងសង់ចូលក្នុងការដ្ឋានសាងសង់។
- អង្គការភ្លែននឹងធ្វើការទូទាត់ប្រាក់លើកទី២ចំនួន៥០% នៃចំនួនទឹកប្រាក់សរុប បន្ទាប់ពីអ្នកម៉ៅការសាងសង់ឧបករណ៍លាងសម្អាតដៃដោយជើងបានចំនួន៩០ និងបានដឹកឧបករណ៍ទាំងនេះទៅដល់ទីតាំងនីមួយៗ បានចំនួន៥០%។
- អង្គការភ្លែននឹងធ្វើការទូទាត់ប្រាក់លើកទី៣ចំនួន២៥% នៃចំនួនទឹកប្រាក់សរុប បន្ទាប់ពីអ្នកម៉ៅការសាងសង់ឧបករណ៍លាងសម្អាតដៃដោយជើងបានចំនួន៩០ បន្ថែមទៀត និងបានដឹកឧបករណ៍ទាំងនេះទៅដល់ទីតាំងនីមួយៗ បានចំនួន១០០%។
- អង្គការភ្លែននឹងធ្វើការទូទាត់ប្រាក់លើកទី៤ចំនួន៥% នៃចំនួនទឹកប្រាក់សរុប បន្ទាប់ពីរយៈពេលធានាចំនួន ០១ខែក្រោយពេលតំឡើងរួច។

**អ្នកដេញថ្លៃទាំងអស់ត្រូវអានសេចក្តីណែនាំការងារដេញថ្លៃអោយយល់សព្វគ្រប់មុននឹងរៀបចំឯកសារដេញថ្លៃ ៖**

១. នៅលើស្រោមសំបុត្រឯកសារដេញថ្លៃត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកដេញថ្លៃឲ្យបានច្បាស់លាស់។
២. នៅលើស្រោមសំបុត្រឯកសារដេញថ្លៃត្រូវសរសេរសរសេរ **"ឯកសារដេញថ្លៃគម្រោងសាងសង់ឧបករណ៍លាងសម្អាតដៃ ដោយជើងនៅតាមសាលារៀន ចំនួន១៨០"**។
៣. សរសេរពាក្យ "មិនត្រូវបើកមុនកាលបរិច្ឆេទកំណត់នៃការបើកឯកសារដេញថ្លៃឡើយ"។
៤. ត្រូវប្រថាប់ត្រាក្រុមហ៊ុន នៅលើមាត់ស្រោមសំបុត្រដែលបិទរួច។
៥. សូមដាក់លេខយោងឯកសារដេញថ្លៃ [FY22-IFB003] - [ឈ្មោះក្រុមហ៊ុន/អ្នកដេញថ្លៃ] សម្រាប់ការឆ្លើយឆ្លងក្នុងការដេញថ្លៃទាំងអស់។

**កាលបរិច្ឆេទទទួលសំណើដេញថ្លៃ និងដាក់សំណើដេញថ្លៃ ៖**

- ស្ថាប័ន ក្រុមហ៊ុន អ្នកម៉ៅការ ឬ សិប្បកម្ម ទាំងអស់ដែលមានចំណាប់អារម្មណ៍ចូលរួមដេញថ្លៃ សូមអញ្ជើញមកទទួលយកឯកសារដេញថ្លៃដោយឥតគិតថ្លៃតាមអាសយដ្ឋានខាងក្រោម នៅរៀងរាល់ម៉ោងធ្វើការ (ម៉ោង៧:៣០នាទីព្រឹក ដល់ម៉ោង ៥:០០នាទីល្ងាច)។
- អ្នកចូលរួមដេញថ្លៃ ត្រូវដាក់ឯកសារដេញថ្លៃទៅការិយាល័យអង្គការភ្លែនភ្នំពេញ ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃ **ទី២៥ ខែ កុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោង ១៧:០០នាទី** ជាកំហិត។

**ទីកន្លែងប្រជុំបើកសំណើដេញថ្លៃ ៖**

ការិយាល័យអង្គការភ្លែនអន្តរជាតិកម្ពុជា៖ ជាន់ទី១៣ (G1309-G1312), GIA Tower ផ្លូវសុភក្រមង្គល កោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ។

**សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោង ទីតាំង និងបច្ចេកទេសសាងសង់ សូមទំនាក់ទំនង ៖**

ទូរសព្ទ៖ (+៨៥៥) ១២ ៨៧៦ ២៨៧
អ៊ីម៉ែល៖ Hybunna.Hang@plan-international.org

**សម្រាប់ព័ត៌មានបន្ថែមអំពីការដេញថ្លៃ សូមទំនាក់ទំនង ៖**

ទូរសព្ទ៖ (+៨៥៥) ១៦ ៩០៤ ៨៩៩
អ៊ីម៉ែល៖ Soniteh.Ponn@plan-international.org

**កំណត់សំគាល់ ៖**

អ្នកទទួលការរបស់ស្ថាប័ន ក្រុមហ៊ុន អ្នកម៉ៅការ ឬ សិប្បកម្ម ត្រូវប្រាកដថាខ្លួនបានដឹងនិងយល់ពត៌មានដេញថ្លៃច្បាស់លាស់ មុននឹងដាក់ពាក្យដេញថ្លៃ។ អ្នកទទួលការត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ុមគ្រលំគ្នា និងមិនពាក់ពន្ធ័នឹងការក្លែងបន្លំ ឬអំពើពុករលួយ ណាមួយឡើយ។ ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ុមគ្រលំគ្នា ឬពាក់ពន្ធ័ក្នុងការក្លែងបន្លំ ឬអំពើពុករលួយជាមួយអ្នកទទួលការដទៃ អ្នកទទួលការទាំងនោះ នឹងមិនត្រូវបានអនុញ្ញាតអោយដាក់សំណើដេញថ្លៃគម្រោងជាមួយអង្គការភ្លែនអន្តរជាតិ នៅពេលអនាគតទៀតឡើយ។

# ផ្នែកទី ២ ៖
# សេចក្តីណែនាំចំពោះអ្នកចូលរួមដេញថ្លៃ

**អ្នកដេញថ្លៃទាំងអស់ត្រូវអានសេចក្តីណែនាំការងារដេញថ្លៃអោយយល់សព្វគ្រប់មុននឹងរៀបចំឯកសារដេញថ្លៃ**

១. នៅលើស្រោមសំបុត្រឯកសារដេញថ្លៃត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកដេញថ្លៃឲ្យបានច្បាស់លាស់។

២. នៅលើស្រោមសំបុត្រឯកសារដេញថ្លៃត្រូវសរសេរសរសេរ **"ឯកសារដេញថ្លៃគម្រោងសាងសង់ឧបករណ៍លាងសម្អាតដៃ ដោយជើងនៅតាមសាលារៀន ចំនួន១៨០"**។

៣. សរសេរពាក្យ "មិនត្រូវបើកមុនកាលបរិច្ឆេទកំណត់នៃការបើកឯកសារដេញថ្លៃឡើយ"។

៤. ត្រូវប្រថាប់ត្រាក្រុមហ៊ុន នៅលើមាត់ស្រោមសំបុត្រដែលបិទរួច។

៥. សូមដាក់លេខយោងឯកសារដេញថ្លៃ [FY22-IFB003] - [ឈ្មោះក្រុមហ៊ុន/អ្នកដេញថ្លៃ] សម្រាប់ការឆ្លើយឆ្លងក្នុងការដេញថ្លៃទាំងអស់។

**តារាងបញ្ជាក់អំពីទីតាំងគម្រោងសាងសង់ និងតំឡើងឧបករណ៍លាងសម្អាតដៃដោយជើងនៅតាមសាលារៀន**

| ល.រ | ឈ្មោះស្រុក | សាលារៀន | ចំនួនឧបករណ៍លាងសម្អាតដៃដោយជើង |
|---|---|---|---|
| ១ | ក្រុងព្រះសីហនុ | ១៨ | ៣៦ |
| ២ | ស្រុកព្រៃនប់ | ៤២ | ៨៤ |
| ៣ | ស្រុកស្ទឹងហាវ | ១០ | ២០ |
| ៤ | ស្រុកកំពង់សិលា | ២០ | ៤០ |
| **សរុប** | | **៩០** | **១៨០** |

## ក. សេចក្តីណែនាំចំពោះអ្នកចូលរួមដេញថ្លៃ

**1. ទំហំការងារដេញថ្លៃ**

1.1. អង្គការភ្លែនអន្តរជាតិកម្ពុជា តទៅនេះហៅថាភាគីប្រគល់ការងារម៉ៅការ សូមអញ្ជើញស្ថាប័ន ក្រុមហ៊ុន អ្នកម៉ៅការ ឬ សិប្បកម្ម ទាំងអស់ដែលមានចំណាប់អារម្មណ៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចូលរួមដេញថ្លៃ "គម្រោងសាងសង់ឧបករណ៍លាងសម្អាតដៃ ដោយជើងនៅតាមសាលារៀន"។

1.2. ទីតាំងសាងសង់មានបញ្ជាក់ជូននៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងលិខិតអញ្ជើញដេញថ្លៃ។

1.3. ចំពោះស្ថាប័ន ក្រុមហ៊ុន អ្នកម៉ៅការ ឬ សិប្បកម្មទទួលបានជោគជ័យ នឹងត្រូវបំពេញការងារឲ្យបានសព្វគ្រប់ក្នុង រយៈពេលដូចបានបញ្ជាក់ជូនក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងឯកសារដេញថ្លៃ។

**2. អ្នកដេញថ្លៃស្របច្បាប់**

2.1 ការដេញថ្លៃគឺអញ្ជើញជាចំហរ ចំពោះអ្នកដេញថ្លៃស្របច្បាប់ទាំងអស់ដែលបានបំពេញនូវតំរូវការដូចខាងក្រោម៖

a. អ្នកដេញថ្លៃដែលរួមមានសមាជិកផ្សេងទៀតនៃក្រុមហ៊ុនជាដៃគូ ប៉ុន្តែមិនត្រូវផ្សារភ្ជាប់ ជាមួយ ក្រុមហ៊ុនដែលធ្លាប់ផ្តល់សេវាកម្មអ្នកពិគ្រោះការក្នុងកំឡុងពេលបំពេញការងារ ឬគម្រោងផ្នែក ណាមួយដែលធ្លាប់បានជួល ឬ បានរៀបចំគម្រោងសំរាប់ជួលដូចជាវិស្វករ ជាប់កិច្ចសន្យា។

b. អ្នកដេញថ្លៃត្រូវច្បាស់ថាក្រុមហ៊ុនមិនស៊ីសំណូក និង មិនអនុវត្តន៍ការងារលួចបន្លំ។

2.2 អ្នកដេញថ្លៃត្រូវផ្តល់ឯកសារភ័ស្តុតាងស្របច្បាប់គ្រប់គ្រាន់ទៅអ្នកប្រគល់ការម៉ៅការតាមសំណើរ។

**3. គុណសម្បត្តិនៃអ្នកចូលរួមដេញថ្លៃ**

អ្នកចូលរួមដេញថ្លៃទាំងអស់ត្រូវផ្តល់ព័ត៌មានជាមួយនឹងឯកសារដេញថ្លៃរបស់ខ្លួនដូចខាងក្រោម៖

- ត្រូវមានវិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬជាមួយក្រសួងពាក់ពន្ធ័ (សម្រាប់ក្រុមហ៊ុន)។

- ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការម៉ៅការរបស់សាលាក្រុង ឬខេត្ត និងនៅមានសុពលភាព។
- ត្រូវមានប័ណ្ណប៉ាតង់សម្រាប់ឆ្នាំ២០២១ និង ឆ្នាំ២០២២ (ប្រសិនបើមាន) (សម្រាប់ក្រុមហ៊ុន)។
- ត្រូវមានបទពិសោធន៍យ៉ាងតិច០១ឆ្នាំ ក្នុងការផលិតគ្រឿងដែក ហើយត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាដែលក្រុមហ៊ុនបានធ្វើជាមួយអង្គការ ឬស្ថាប័នទាំងនោះដោយត្រូវភ្ជាប់មកជាមួយនូវរូបថតពណ៌ បង្ហាញពីស្នាដៃការងារនៃកិច្ចសន្យានោះ។
- ត្រូវមានអ្នកធានាយ៉ាងតិច០២នាក់ (ដោយប្រាប់ពីឈ្មោះ ទីកន្លែងធ្វើការ មុខងារ និងលេខទូរស័ព្ទទំនាក់ទំនង)។

4. **ឧបករណ៍ គ្រឿងចក្រ និង សេវាកម្មស្របច្បាប់**

ឧបករណ៍គ្រឿងចក្រ និងសេវាកម្មដែលត្រូវផ្តល់តាមកិច្ចសន្យាត្រូវស្ថិតក្នុងព្រំដែននៃប្រភេទស្របច្បាប់ ហើយរាល់ការចំណាយដែលលើកឡើងក្រោមកិច្ចសន្យា នឹងមានកំណត់នូវសំភារៈគ្រឿងចក្រ និង សេវាកម្មទាំងនោះ។ ក្នុងការស្នើរបស់ភាគីប្រគល់ការងារម៉ៅការ អ្នកដេញថ្លៃទាំងអស់ត្រូវ ផ្តល់ភស្តុតាងនៃប្រភពសំភារៈគ្រឿងចក្រនិងសេវាកម្មទាំងអស់នោះ។

5. **ឯកសារដេញថ្លៃ**

ឯកសារដេញថ្លៃត្រូវដាក់នៅក្នុងកញ្ចប់តែមួយ រួចបិទឲ្យជិត និងបោះត្រាក្រុមហ៊ុន ឬចុះហត្ថលេខានៅត្រង់មាត់សំបុត្រ។

6. **ការបំពេញតំលៃ**

អ្នកដេញថ្លៃត្រូវទទួលស្គាល់តំលៃដែលបានបំពេញក្នុងឯកសារដេញថ្លៃរបស់ខ្លួន។ ប្រសិនបើមានការកែប្រែ ឬ ស្នាមលុប ភាគីប្រគល់ការងារម៉ៅការមិនទទួលខុសត្រូវនូវករណីទាំងនេះឡើយ។

7. **ការពិនិត្យការដ្ឋាន ឬកន្លែងផលិត**

អ្នកដេញថ្លៃត្រូវទៅពិនិត្យការដ្ឋានស្វែងយល់នូវការងារសាងសង់ ឧបករណ៍គំរូ និងព័ត៌មាននានា នៅសាលាបឋមសិក្សាចៅពញាហុក។ ការពិនិត្យការដ្ឋានជាការទទួលខុសត្រូវរបស់អ្នកដេញថ្លៃ។ ព័ត៌មានដែលទទួលបានពីការពិនិត្យនោះអាចជាប្រយោជន៍សំខាន់ក្នុងការរៀបចំឯកសារដេញថ្លៃរបស់អ្នកដេញថ្លៃ។

8. **មាតិកានៃឯកសារដេញថ្លៃ**

8.1 ឯកសារដេញថ្លៃមួយច្បាប់ រួមមានឯកសារតូចៗជាច្រើនដែលមាននៅក្នុងតារាងខាងក្រោមផង៖

ផ្នែកទី១ លិខិតអញ្ជើញដេញថ្លៃ

ផ្នែកទី២ សេចក្តីណែនាំចំពោះអ្នកចូលរួមដេញថ្លៃ

ផ្នែកទី៣ លិខិតប្រកាសទទួលស្គាល់របស់អ្នកដេញថ្លៃ

ផ្នែកទី៤ ទំរង់បែបបទនៃលក្ខណៈសម្បត្តិរបស់អ្នកម៉ៅការ

ផ្នែកទី៥ បទដ្ឋានបច្ចេកទេស និងសេចក្តីលំអិតសម្ភារៈសំណង់

ផ្នែកទី៦ បញ្ជីរាយចំណាយលើសម្ភារៈនិងពលកម្ម

ផ្នែកទី៧ គំនូរប្លង់

8.2 អ្នកដេញថ្លៃត្រូវពិនិត្យមាតិកានៃឯកសារដេញថ្លៃដោយយកចិត្តទុកដាក់បំផុត។ កំហុសដែលពុំបានបំពេញតាមសំណើរនៃការដេញថ្លៃគឺជាកំហុសរបស់អ្នកដេញថ្លៃផ្ទាល់។ ដោយអនុលោមតាមប្រការ ២៧ ឯកសារដេញថ្លៃណាដែលមិនបានបំពេញតាមសំណើ នៃឯកសារដេញថ្លៃ នឹងទុកជាមោឃៈ។

9. **ការបំភ្លឺបន្ថែមនៃឯកសារដេញថ្លៃ**

ការបំភ្លឺបន្ថែមទាំងឡាយនៃឯកសារដេញថ្លៃ របស់ក្រុមហ៊ុនណាមួយអាចសរសេរជាលាយលក្ខ័អក្សរ ឬ តាមរយៈទូរសារមកកាន់អ្នកបច្ចេទេសរបស់អង្គការភ្លែន តាមរយៈអាស័យដ្ឋានដែលមានបញ្ជាក់ក្នុងឯកសារដេញថ្លៃឲ្យបានមួយ (០១)ថ្ងៃ មុនថ្ងៃឈប់ទទួលកញ្ចប់ដេញថ្លៃ។ អ្នកបច្ចេទេសរបស់អង្គការភ្លែន នឹងឆ្លើយតបទៅនឹងសំណើផ្សេងៗដែលស្នើ ដោយអ្នកដេញថ្លៃ។

10. **ការកែប្រែឯកសារដេញថ្លៃ**

11.1 មុនកាលបរិច្ឆេទផុតកំណត់ឈប់ទទួលឯកសារដេញថ្លៃ "អង្គការភ្លែន" អាចកែប្រែឯកសារដេញថ្លៃ មួយចំនួនដោយត្រូវជូនឯកសារបំពេញបន្ថែម។

11.2 រាល់ឯកសារដែលកែប្រែត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារដេញថ្លៃដែរ។ ហើយត្រូវផ្ញើជាលាយល័ក្ខអក្សរ ឬ ជាទូរសារទៅកាន់អ្នកទទួលឯកសារដេញថ្លៃទាំងអស់។ បន្ទាប់ពីបានទទួល ឯកសារ កែប្រែ អ្នកទទួលឯកសារដេញថ្លៃទាំងអស់ត្រូវផ្ញើរជាលាយល័ក្ខអក្សរ ឬ ជាទូរសារមកកាន់ភាគី ប្រគល់ការងារម៉ៅការ ថាខ្លួនបានទទួលនូវឯកសារកែប្រែទាំងនោះហើយ។ ប្រសិនមិនមានព័ត៌មានមកទេ ភាគីប្រគល់ការងារម៉ៅការចាត់ទុកថាអ្នកដេញថ្លៃបានទទួល រួចហើយ។

11.3 ដើម្បីផ្តល់ពេលវេលាសមរម្យ ដល់អ្នកចូលដេញថ្លៃក្នុងការកែប្រែ និង រយៈពេលនៃការរៀបចំឯកសារដេញថ្លៃ ភាគីប្រគល់ការងារម៉ៅការនឹងពន្យាពេលចាំបាច់សំរាប់កំណត់ពេលវេលាឈប់ ទទួលពាក្យដេញថ្លៃ។

## ខ. ការរៀបចំឯកសារដេញថ្លៃ

### 11. ភាសា

ឯកសារទាំងអស់ដែលទាក់ទងនឹងឯកសារដេញថ្លៃ គឺជាឯកសារសរសេរជាភាសាខ្មែរ លើកលែងតែពាក្យបច្ចេកទេសប៉ុណ្ណោះ។

### 12. ឯកសារដែលដាក់ក្នុងការដេញថ្លៃ

ឯកសារដេញថ្លៃដែលត្រូវបញ្ជូនមករួមមាន៖

a. សេចក្តីប្រកាសទទួលស្គាល់អ្នកដេញថ្លៃ។

b. ទម្រង់បែបបទនៃព័តមានអំពីគុណសម្បត្តិរបស់ស្ថាប័ន ក្រុមហ៊ុន អ្នកម៉ៅការ ឬ សិប្បកម្ម ភ្ជាប់ជាមួយវិញ្ញាបនប័ត្រក្រុមហ៊ុន និង ប្រតិទិនការងារ។

c. បញ្ជីរប៉ាន់ស្មានដែលមានចុះតំលៃរួចស្របជាមួយសេចក្តីណែនាំអំពីសម្ភារៈផ្សេងៗ ដែលចាំបាច់ សំរាប់ការងារដែលត្រូវអនុវត្ត។ ប្រសិនបើអ្នកដេញថ្លៃបញ្ជូនឯកសារមកដោយមិនបានបំពេញនូវចំនុចខាងលើកនេះទេ ឯកសារដេញថ្លៃនោះនឹងត្រូវចាត់ទុកជាមោឃៈ។

### 13. តំលៃដាក់ដេញថ្លៃ

13.1 បើគ្មានការបញ្ជាក់បន្ថែមក្នុងឯកសារដេញថ្លៃទេ កិច្ចសន្យានឹងប្រើប្រាស់សំរាប់ការងារទាំងអស់ដូចដែលបានកំណត់យកជាមូលដ្ឋានលើបញ្ជីរប៉ាន់តំលៃដែលបានបំពេញរួចដោយ ភាគីដេញថ្លៃ។

13.2 ភាគីដេញថ្លៃត្រូវបំពេញក្នុងតារាង លើអាត្រាលើគ្រប់ចំណុចទាំងអស់នៃទំហំការងារដែលបានរៀបរាប់ក្នុងគំនូរប្លង់ និង បទដ្ឋានបច្ចេទេសហើយបានរាយក្នុងបញ្ជីរប៉ាន់ស្មានតំលៃ។ ចំនុចណា ដែលមិនបានបំពេញនឹងមិនត្រូវបានការទូទាត់ដោយភាគីប្រគល់ការងារម៉ៅការទេ ហើយត្រូវបានសន្មត់ ថាបានបញ្ចូលទៅក្នុងការចំណាយលើមុខសម្ភារៈផ្សេងៗ ក្នុងបញ្ជីប៉ាន់ស្មានសម្ភារៈរួចហើយ។

13.3 តំលៃសរុបដែលភាគីដេញថ្លៃបានដាក់មកគឺជាតំលៃមិនកែប្រែក្នុងរយៈពេលអនុវត្តកិច្ចសន្យា និង មិនអាចកែប្រែបានក្នុងបញ្ជីនោះឡើយ។

### 14. រូបបិយប័ណ្ណដែលប្រើក្នុងការទូទាត់លើការដេញថ្លៃ

តំលៃសរុបដែលភាគីដេញថ្លៃដាក់មកត្រូវគិតជារូបបិយប័ណ្ណដុល្លាសហរដ្ឋអាមេរិកទាំងអស់។

### 15. សុពលភាពនៃការដេញថ្លៃ

15.1 ការដេញថ្លៃត្រូវរក្សាទុកបានការសំរាប់រយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានចែងក្នុងទិន្នន័យដេញថ្លៃ (ឯកសារដេញថ្លៃ) បន្ទាប់ពីថ្ងៃបើកឲ្យដេញថ្លៃ។

15.2 ក្នុងករណីលើកលែង មុនពេលផុតកំណត់នៃការដេញថ្លៃ និយោជកអាចស្នើសុំឲ្យមានការពន្យាពេលតទៅទៀតដោយស្នើទៅអ្នកចូលរួមដេញថ្លៃជាលាយល័ក្ខអក្សរ រឺតាមទំនាក់ទំនងផ្សេងទៀត ភាគីអ្នកដេញថ្លៃដែលឯកភាពនឹងសំនើរនឹងមិនអនុញ្ញាតិឲ្យកែឯកសារដេញថ្លៃឡើយ។

### 16. សំណើរសុំផ្លាស់ប្តូររបស់ភាគីដេញថ្លៃ

ភាគីដេញថ្លៃដែលមានបំណងផ្លាស់ប្តូរលក្ខណៈបច្ចេទេសក្នុងឯកសារដេញថ្លៃ ត្រូវសំណើរដាក់ក្នុង ឯកសារដេញថ្លៃ ដែលស្របតាមឯកសារដេញថ្លៃ រួមមានលក្ខណៈបច្ចេទេសជាមូលដ្ឋាន ដូចបាន បញ្ជាក់ក្នុងគំនូសប្លង់ និង បទដ្ឋានបច្ចេកទេស។

ភាគីប្រគល់ការងារម៉ៅការ នឹងពិចារណាលើការ ស្នើសុំផ្លាស់ប្តូររបស់អ្នកដេញថ្លៃណាដែលត្រូវ វាយតំលៃថាសមហេតុផល និង តំលៃសមរម្យ។

**17. ទំរង់ឯកសារដេញថ្លៃនិងការចុះហត្ថលេខា**

17.1 អ្នកដេញថ្លៃត្រូវរៀបចំឯកសារច្បាប់ដើមមួយច្បាប់ ដែលមានឯកសារដេញថ្លៃដូចបានបញ្ជាក់ជូនក្នុងប្រការ១៣ នៃសេចក្តីណែនាំសំរាប់ការដេញថ្លៃ។

17.2 ច្បាប់ដើម និង ឯកសារចំលងដេញថ្លៃទាំងអស់ត្រូវសរសេរដោយដៃ រឺវាយដោយទឹកថ្នាំដែលមិនអាចលុបបាន ហើយត្រូវចុះហត្ថលេខាដោយតំណាងម្នាក់របស់អ្នកចូលរួមដេញថ្លៃ។ គ្រប់ទំព័រនៃ ឯកសារដេញថ្លៃត្រង់ផ្នែក រឺ ចំណុចណាដែលមានការកែប្រែ រឺ បន្ថែមថ្មីត្រូវតែដោយតំណាងដែល បានចុះហត្ថលេខាលើឯកសារទាំងអស់នោះ។

17.3 ឯកសារដេញថ្លៃដែលមិនមានការកែប្រែ រឺ បន្ថែមថ្មីលើកលែងតែឯកសារណាដែលជាបទបញ្ជារចេញដោយភាគីប្រគល់ការងារម៉ៅការ ឬ ក៏ជាការកែតំរូវចាំបាច់ដែលឡើងដោយអ្នកដេញថ្លៃក្នុងករណីនេះត្រូវមានការចុះហត្ថលេខាពីបុគ្គលដែលបានចុះហត្ថលេខាក្នុងឯកសារដេញថ្លៃ។

## គ. ការរៀបចំ និង ដាក់ជូននូវឯកសារដេញថ្លៃ

**18. ការភ្ជឹតស្រោមសំបុត្រ និង គូសចំណាំនៃឯកសារដេញថ្លៃ**

18.1 អ្នកដេញថ្លៃត្រូវដាក់ឯកសារដេញថ្លៃជាច្បាប់ដើមក្នុងស្រោមសំបុត្រ ហើយបិទជិត និង ការខ្ទង់សំបុត្រដោយសរសេរអោយបានត្រឹមត្រូវដូចខាងក្រោម៖

a. នៅលើស្រោមសំបុត្រឯកសារដេញថ្លៃត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកដេញថ្លៃឲ្យបានច្បាស់លាស់

b. នៅលើស្រោមសំបុត្រឯកសារដេញថ្លៃ ត្រូវសរសេរសរសេរ "**ឯកសារដេញថ្លៃគម្រោងផលិតឧបករណ៍លាងសម្អាតដៃដោយជើងនៅតាមសាលារៀន**"។

c. សរសេរពាក្យ "មិនត្រូវបើកមុនកាលបរិច្ឆេទកំណត់នៃការបើកឯកសារដេញថ្លៃឡើយ"។

d. ត្រូវប្រថាប់ត្រាក្រុមហ៊ុន នៅលើមាត់ស្រោមសំបុត្រដែលបិទរួច។

18.2 បើសិនស្រោមសំបុត្រមិនបានបិទជិតភាគីប្រគល់កាងារម៉ៅការមិនទទួលខុសត្រូវចំពោះកំហុស ឆ្គងនៅពេលបើកឯកសារដេញថ្លៃឡើយ។

**19. កាលបរិច្ឆេទនៃការដាក់ពាក្យចូលដេញថ្លៃ**

19.1 ពាក្យចូលដេញថ្លៃត្រូវផ្ញើរជូនមក តាមអាស័យដ្ឋានដែលមានបញ្ជាក់ នៅក្នុងចំនុចទី18.2 ដែលមិនឲ្យយឺតជាងកាលបរិច្ឆេទដែលបានកំណត់នៅក្នុងទិន្នន័យដេញថ្លៃ។

19.2 ក្នុងករណីពិសេសចាំបាច់បំផុត និយោជកអាចបន្តកាលបរិច្ឆេទ នៃការដាក់ពាក្យចូលដេញថ្លៃបាន ដោយជូនលិខិតជូនដំណឹងពន្យាពេល។ ក្នុងករណីនេះអ្នកដេញថ្លៃត្រូវគោរពតាមរយៈពេលផុត កំណត់ដែលបានជូនដំណឹងពីពេលមុនរហូតលុះត្រាមានការកំណត់ពេលជាថ្មី។

**20. ពាក្យសុំដេញថ្លៃដែលដាក់មកយឺត**

រាល់ពាក្យសុំដេញថ្លៃណាដែលនិយោជកបានទទួលក្រោយកាលបរិច្ឆេទផុតកំណត់ដេញថ្លៃ ដូចដែលមានបញ្ជាក់ក្នុងមាត្រា 19 នឹងត្រូវបញ្ជូនត្រលប់ទៅវិញ ក្នុងស្រោមសំបុត្រដដែលដោយមិន អនុញ្ញាតិឲ្យចូលរួមដេញថ្លៃទេ។

**21. ការកែប្រែ ការជំនួស និង ការដកថយពីការដេញថ្លៃ**

21.1 មិនអាចកែប្រែឯកសារដេញថ្លៃឡើយក្រោយកាលបរិច្ឆេទឈប់ទទួលពាក្យដេញថ្លៃ។

21.2 មិនត្រូវដកឯកសារដេញថ្លៃនៅចន្លោះពេលផុតកំណត់នៃការដាក់ឯកសារ និង ពេលផុតកំណត់ សុពលភាពដេញ ថ្លៃដែលមានបញ្ជាក់ក្នុងទំរង់នៃកាដេញថ្លៃឡើយ។

## ឃ. ដំណើរការបើកសំបុត្រដេញថ្លៃ និង ការវាយតំលៃ

**22. ការបើកសំបុត្រដេញថ្លៃ**

22.1 អង្គការនឹងការបើកឯកសារដេញថ្លៃនៅចំពោះមុខតំណាងអ្នកចូលរួម ទៅតាមពេលវេលា និង ទីកន្លែងដូចដែលបានកំណត់។

22.2 ការិយាល័យអង្គការភ្លែនអន្តជាតិនៅភ្នំពេញជាអ្នករៀបចំការដេញថ្លៃនោះ។

22.3 ភាគីប្រគល់ការងារម៉ៅការ នឹងរៀបចំកំណត់ហេតុនិងប្រកាសពត័មានជាសាធារណៈចំពោះមុខអ្នកចូលរួមដេញថ្លៃទាំងអស់។

## 23. ដំណើរការត្រូវចាត់ទុកជាការសម្ងាត់

ពត័មានទាំងឡាយណាដែលទាក់ទងទៅការត្រួតពិនិត្យ ការបំភ្លឺ ការវាយតំលៃ និង ការប្រៀប ធៀបនៃឯកសារដេញថ្លៃ ព្រមទាំងអនុសាសន៍នៃការសំរេចឲ្យចុះកិច្ចសន្យា នឹងមិនជំរាបជូនឲ្យទៅភាគីអ្នកដេញថ្លៃ រឺ បុគ្គលណាដែលមិនពាក់ពន្ធជាផ្លូវការជាមួយដំណើរការនេះឡើយ រហូត ដល់ការប្រកាសឈ្មោះអ្នកឈ្នះការដេញថ្លៃ ។ ការខិតខំផ្សេងៗរបស់ភាគីអ្នកដេញថ្លៃណាមួយ ដែលអោយមានឥទ្ធិពលលើភាគីប្រគល់ការងារម៉ៅការ រឺ តំណាងភាគីប្រគលការងារម៉ៅការក្នុង ដំណើរការដេញថ្លៃ រឺ ក្នុងការសំរេចដោយចុះកិច្ចសន្យានឹងអាចឯកសារដេញថ្លៃ របស់អ្នកដេញ ថ្លៃ នោះទុកជាមិនបានការ។

## 24. ការបំភ្លឺបន្ថែមនៃឯកសារដេញថ្លៃ

- ក្នុងការត្រួតពិនិត្យវាយតំលៃប្រៀបធៀបឯកសារដេញថ្លៃ និយោជកអាចស្នើសុំរាល់អ្នកដេញថ្លៃ មួយណាក៏ដោយ ដើម្បីការពន្យល់បកស្រាយរួមទាំងការគណនាលំអិតទៅលើបរិមាណ រឺ អត្រាឯកត្តាជាដើម។
- គ្មានអ្នកដេញថ្លៃណាមួយអាចទាក់ទងជាមួយ ភាគីប្រគល់ការងារដេញថ្លៃក្នុងរយៈពេលបើកឯកសារដេញថ្លៃ រហូតដល់ពេលប្រកាសលទ្ធផល និង ប្រគល់កិច្ចសន្យា។ បើអ្នកដេញថ្លៃណាមាន បំណងចង់ទាក់ទងនិយោជកដើម្បីបញ្ហាផ្សេងៗដែលទាក់ទងទៅនឹងការដេញថ្លៃ រឺ កិច្ចសន្យាគឺ អាចបានជាលាយល័ក្ខអក្សរ។
- ការខ្នះខ្នែងផ្សេងៗ របស់អ្នកដេញថ្លៃដែលមានឥទ្ធិពលដល់ភាគីប្រគល់ការងារម៉ៅការនៅក្នុង ការវាយតំលៃការប្រៀបធៀបឯកសារ ឬ ការសំរេចប្រគល់កិច្ចសន្យាអាចជាលទ្ធផល បដិសេធន៍នៃ ឯកសារដេញថ្លៃរបស់អ្នកដេញថ្លៃនោះ។

## 25. ការត្រួតពិនិត្យឯកសារដាក់ដេញថ្លៃ

25.1 មុនពេលដែលការវាយតំលៃលំអិតនៃការដេញថ្លៃ ភាគី ប្រគល់ការងារម៉ៅការនឹងពិនិត្យបញ្ជាក់លើឯកសារនីមួយៗថាតើ៖

   a. ឯកសារគ្រប់គ្រាន់ហើយមានចុះហត្ថលេខាត្រឹមត្រូវរឺទេ?
   b. មានការឆ្លើយតបត្រឹមត្រូវទៅនឹងតំរូវការដូចដែលមានចែងក្នុងឯកសារដេញថ្លៃរឺទេ?

25.2 ការឆ្លើយតបត្រឹមត្រូវរបស់ឯកសារដេញថ្លៃ គឺឆ្លើយតបគ្រប់ចំណុចគ្រប់លក្ខខ័ណ្ឌ បទដ្ឋានទាំងអស់ដោយគ្មានការគិតច្រឡំ ឬ កាត់បន្ថយសំភារៈសាងសង់ឡើយ។

25.3 ប្រសិនបើឯកសារដេញថ្លៃណាដែលមិនមានការឆ្លើយតបត្រឹមត្រូវទេ ឯកសារដេញថ្លៃនោះនឹងត្រូវបដិសេធចោលដោយភាគីប្រគល់ការងារម៉ៅការ ហើយនឹងមិនអនុញ្ញាតឲ្យកែតម្រូវអនុលោមតាម ការគិតច្រឡំឡើយ។

## 26. ការកែតម្រូវកំហុស

26.1 ឯកសារសុំដេញថ្លៃដែលត្រូវបានកំណត់ថាត្រឹមត្រូវ នឹងត្រូវបានត្រួតពិនិត្យដោយភាគីប្រគល់ការងារម៉ៅការសំរាប់ការគិតលេខភាន់ច្រឡំណាមួយ។ ការភាន់ច្រឡំនឹងត្រូវកែប្រែវិញដោយភាគីប្រគល់ការងារម៉ៅការដូចតទៅ៖

   a. នៅត្រង់ចំណុចដែលមានការខុសគ្នារវាងបរិមាណដែលសរសេរជាលេខ និង សរសេរជាអក្សរ។ តំលៃជាអក្សរមានតំលៃជាងនឹងយកជាបានការ។
   b. នៅត្រង់ចំណុចដែលមានការខុសគ្នារវាង តំលៃរាយ និង តំលៃសរុប និង តំលៃសរុបនៃចំនួនមួយ ការបូកតំលៃរាយឡើងវិញចាត់ទុកជាបានការ។

26.2 តំលៃសរុបដែលបានដាក់ក្នុងឯកសារដេញថ្លៃដេញថ្លៃ នឹងត្រូវបានកែតំរូវដោយភាគី ប្រគល់ការងារម៉ៅការ ដោយអនុលោមតាមដំណើរការខាងលើ។ រាល់ការកែតម្រូវនៃការ ភាន់ច្រឡំ នឹងមានការយល់ព្រមជាមួយអ្នកចូលដេញថ្លៃ ប្រសិនបើអ្នកដេញថ្លៃ មិនយល់ព្រមចំពោះ លើតំលៃសរុបដែល បានកែតំរូវឯកសារដាក់ដេញថ្លៃ នោះនឹងត្រូវបានបដិសេធចោល។

**27. ការវាយតំលៃ និង ការប្រៀបធៀបឯកសារដេញថ្លៃ**

27.1 ភាគីប្រគល់ការងារម៉ៅការការវាយតំលៃ និងប្រៀបធៀបតែលើឯកសារដេញថ្លៃ ណាដែលបញ្ជាក់ថា មានការឆ្លើយតប ត្រឹមត្រូវប៉ុណ្ណោះ ដូចដែលមានចែងក្នុងមាត្រា២៧។

27.2 ក្នុងពេលវាយតំលៃឯកសារដេញថ្លៃនីមួយៗភាគីប្រគល់ការងារម៉ៅការនឹងធ្វើការប្រៀបធៀបតម្លៃ ដូចខាងក្រោម៖

a. ធ្វើការកែតំរូវកំហុសទាំងឡាយ ដោយអនុលោមទៅតាមមាត្រា២៧

b. ចំនួនថ្ងៃធ្វើការរបស់ក្រុមហ៊ុននីមួយៗ ត្រូវអនុលោមទៅមាត្រាទាំងឡាយដែលមានចែងក្នុងទម្រង់បែបបទនៃកិច្ចព្រមព្រៀង។

c. ធ្វើការសំរបសំរួលគ្នាឲ្យមានការយល់ព្រមផ្លាស់ប្តូរលើការគិតភាន់ច្រលំ។

27.3 ភាគីប្រគល់ការងារម៉ៅការរក្សាសិទ្ធិក្នុងការទទួល រឺ បដិសេធនូវរាល់ការកែប្រែកំហុស រឺ សំណើរផ្លាស់ប្តូរ។ រាល់ការកែប្រែ និង កត្តាដ៏ទៃទៀតណាដែលលើសពីការទាមទារនៃឯកសារដេញថ្លៃ នឹងមិនត្រូវបានយកមកពិចារណាក្នុងការវាយតំលៃទេ។

## ង. ការសំរេចផ្តល់កិច្ចសន្យា

**28. ការផ្តល់កិច្ចសន្យា**

ភាគីប្រគល់ការងារម៉ៅការ នឹងសំរេចផ្តល់កិច្ចសន្យាដល់អ្នកចូលដេញថ្លៃណាដែលឯកសារដេញថ្លៃរបស់គេបានឆ្លើយតបត្រឹមត្រូវហើយមានតំលៃសមរម្យ។ ការសំរេចផ្តល់កិច្ចសន្យានេះត្រូវមានការឯកភាពពីនាយកប្រត្តិបត្តិជាមុនសិន។

**29. សិទ្ធិរបស់និយោជក ក្នុងការទទួល និង បដិសេធពាក្យសុំដេញថ្លៃ**

ភាគីប្រគល់ការងារម៉ៅការមានសិទ្ធិក្នុងការទទួល រឺបដិសេធរាល់ឯកសារដេញថ្លៃណាមួយនឹងលុបចោលដំណើការដេញថ្លៃ និង គម្រោងដេញថ្លៃទាំងអស់ នៅគ្រប់ពេលមុនការសំរេចប្រគល់កិច្ចសន្យាដោយមិនបញ្ជាក់អំពីហេតុផល សកម្មភាពអ្នកម៉ៅការឡើយ។

**30. ការប្រកាសនៃការសំរេចប្រគល់កិច្ចសន្យា**

30.1 មុនពេលផុតកំណត់នៃសុពលភាពដេញថ្លៃដែលបានកំណត់ដោយភាគីប្រគល់ការងារម៉ៅការ ភាគីប្រគល់ការងារម៉ៅការនឹងប្រកាសឈ្មោះក្រុមហ៊ុនដែលទទួលបានជោគជ័យ ជាលាយល័ក្ខអក្សរ រឺ ផ្ញើរទូរសារថាការដេញថ្លៃរបស់គាត់ត្រូវបានទទួលយល់ព្រម។

30.2 ការប្រកាសនូវការសំរេចប្រគល់ផ្តល់កិច្ចសន្យានឹងធ្វើបានលុះត្រាតែស្របទៅនឹងលក្ខខ័ណ្ឌទូទៅនៃកិច្ចសន្យា ។

**31. ការចុះហត្ថលេខាលើកិច្ចសន្យា**

ក្នុងពេលតែមួយដែលភាគីប្រគល់ការងារម៉ៅការជូនដំណឹងថាជាអ្នកដេញថ្លៃដែលទទួលជោគជ័យភាគីប្រគល់ការងារម៉ៅការ នឹងអញ្ជើញភាគីទទួលការងារម៉ៅការដែលទទួលជោគជ័យ មកការិយាល័យអង្គការភ្លែនដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ។

**32. ប្រាក់ធានាក្នុងការសាងសង់**

អ្នកម៉ៅការត្រូវបង្ហាញអំពីចំនួនទឹកប្រាក់ដែលក្រុមហ៊ុនមានក្នុងធនាគារសំរាប់យកមកចំណាយជាមុននៅវគ្គដំបូង។

# ផ្នែកទី ៣ ៖
# ការប្រកាសទទួលស្គាល់អ្នកម៉ៅការ របស់ភាគីម្ចាស់គម្រោង(ទម្រង់ឯកសារដេញថ្លៃ)

**ពីក្រុមហ៊ុនឈ្មោះ**……………………………………………………………………………………………………….

**អាស័យដ្ឋាន**…………………………………………………………………………………………………………

**លេខទូរស័ព្ទ**…………………………………………………………………………………………………………

សូមដាក់ដេញថ្លៃគម្រោងសាងសង់ ឧបករណ៍លាងសម្អាតដៃដោយជើង ចំនួន១៨០ ដែលនឹងត្រូវប្រគល់ និងតំឡើងនៅតាមសាលារៀន ចំនួន៩០សាលារៀន នៅក្នុងស្រុកចំនួន០៤ ក្នុងខេត្តព្រះសីហនុ។ (សូមមើលប្លង់ និងបទដ្ឋានបច្ចេកទេស)

**យើងខ្ញុំសូមបញ្ជាក់ជូនថា ៖**

១. បានពិនិត្យល័ក្ខខ័ណ្ឌទូទៅនៃកិច្ចសន្យា បទដ្ឋានបច្ចេកទេសផលិត និង គំនូរប្លង់បញ្ជីរប៉ាន់ស្មានតំលៃ និង ឯកសារបន្ថែមសម្រាប់បំពេញការងារខាងលើ។ យើងខ្ញុំសូមប្រកាសថានឹងធ្វើការងារឲ្យបានចប់សព្វគ្រប់ និងការកែតំរូវឲ្យបានល្អឡើងវិញនូវរាល់កំហុសផ្សេងៗតាមការដាស់តឿនដែលមានបញ្ជាក់ក្នុងល័ក្ខខ័ណ្ឌទូទៅនៃកិច្ចសន្យា បទដ្ឋានបច្ចេកទេស គំនូសប្លង់ និងបញ្ជីរប៉ាន់តំលៃសម្ភារៈ។ ទឹកប្រាក់ដែលក្រុមហ៊ុនយើងខ្ញុំ បានគណនាសម្រាប់ការផលិតឧបករណ៍លាងសម្អាតដៃដោយជើងនៅតាមសាលារៀន និងដឹកដល់ខេត្ត និងរាជធានីគោលដៅ សរុបទាំងអស់គឺ៖…………………………………… ដុល្លារសហរដ្ឋអាមេរិច (ចំនួនជាអក្សរសរុប…………………………………………………………………… ដុល្លារសហរដ្ឋអាមេរិច)។ ដូចបានបញ្ជាក់ក្នុងបញ្ជីរប៉ាន់ស្មានសម្ភារនៃឯកសារដេញថ្លៃដែលមានភ្ជាប់មកជាមួយ។

២. យើងខ្ញុំទទួលស្គាល់ថា បានយល់សព្វគ្រប់នូវឯកសារដេញថ្លៃ និងឯកភាពថាវាជាផ្នែកមួយនៃឯកសារដេញថ្លៃរបស់យើងខ្ញុំ។

៣. យើងខ្ញុំសូមសន្យាថាប្រសិនឯកសារដេញថ្លៃរបស់យើងខ្ញុំបានទទួលយល់ព្រម ការចាប់ផ្តើមធ្វើការងារ នឹងមិនត្រូវយឺតជាង ១៥ថ្ងៃបន្ទាប់ពីបានទទួលយល់ព្រមជាលាយលក្ខណ៍អក្សរពីភ្លែនអន្តរជាតិ។ កាលបរិច្ឆេទខាងក្រោមនេះ គឺជាចំនួនថ្ងៃសរុបគិតពីថ្ងៃប្រកាសចាប់ផ្តើមការងារដើម្បីចាប់ផ្តើមការងារទាំងអស់ដែលបាន ចែងក្នុងកិច្ចសន្យា។

ចំនួនថ្ងៃដែលត្រូវបញ្ចប់ការងារគឺ……………………………ថ្ងៃ បន្ទាប់ពីថ្ងៃប្រកាសចាប់ផ្តើម។

ឈ្មោះសាក្សី……………………………………………………………………………………………………………

អាស័យដ្ឋាន……………………………………………………………………………………………………………

មុខងារ…………………………………………………………………………………………………………………

លេខទូរស័ព្ទ……………………………………………………………………………………………………………

**កំណត់សំគាល់ ៖** សំណើដេញថ្លៃនេះមានសុពលភាពរយៈពេល ៦០ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ។

ធ្វើនៅថ្ងៃទី………….. ខែ………….. ឆ្នាំ…………..

ហត្ថលេខា ត្រា និង ឈ្មោះអ្នកដេញថ្លៃ

# ផ្នែកទី ៤៖
# ទម្រង់បែបបទព័ត៌មានអំពីគុណសម្បត្តិរបស់ស្ថាប័ន ក្រុមហ៊ុន អ្នកម៉ៅការ ឬ សិប្បកម្ម ដោយមានភ្ជាប់មកជាមួយនូវវិញ្ញាបនប័ត្រក្រុមហ៊ុន

**ទម្រង់បែបបទពណ៌នាអំពីគុណសម្បត្តិរបស់ក្រុមហ៊ុន**

**១. ការបង្កើត និងឯកសារស្របច្បាប់ផ្សេងៗសំរាប់អ្នកចូលដេញថ្លៃ**

ឈ្មោះក្រុមហ៊ុនដេញថ្លៃ៖.......................................................................................................................

បញ្ជីពាណិជ្ជកម្មលេខ៖.........................................................................................................................

ទីកន្លែងចុះបញ្ជី៖..............................................................................................................................

អាស័យដ្ឋានក្រុមហ៊ុន ឬសិប្បកម្ម៖........................................................................................................

ឈ្មោះអ្នកតំណាងជាផ្លូវការ៖..................................................................................................................

ហត្ថលេខា៖.......................................................................................................................................

**២. វិញ្ញាបនប័ត្រដែលត្រូវភ្ជាប់**

ឯកសារថតចំលងត្រូវភ្ជាប់ជាមួយ។ ឯកសារច្បាប់ដើមត្រូវបង្ហាញជូនប្រសិនចាំបាច់។

| ល.រ | ប្រភេទនៃវិញ្ញាបនប័ត្រ | មាន | មិនមាន |
|---|---|---|---|
| ១ | ច្បាប់ថតចំលងវិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬជាមួយក្រសួងពាក់ពន្ធ័។ | | |
| ២ | ច្បាប់ថតចំលងវិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការម៉ៅការរបស់សាលាក្រុង ឬខេត្ត និងនៅមានសុពលភាព។ | | |
| ៣ | ប័ណ្ណប៉ាតង់សម្រាប់ឆ្នាំ២០២១ និង ឆ្នាំ២០២២ (ប្រសិនបើមាន)។ | | |

**៣. ទិន្នន័យហិរញ្ញវត្ថុ**

**ថវិកាសរុបប្រចាំឆ្នាំ នៃការសាងសង់ ២០២០៖ ដុល្លារ**.......................................................................

**ថវិកាសរុបប្រចាំឆ្នាំ នៃការសាងសង់ ២០២១៖ ដុល្លារ**......................................................................

- សូមភ្ជាប់មកជាមួយនូវឈ្មោះ និងអាស័យដ្ឋានរបស់អ្នកចាត់ចែងធានាគារដែលអាចយកព័ត៌មានបាន...................... ..................................................................................................................................................
- សូមបង្ហាញអំពីថវិការបស់ក្រុមហ៊ុនដែលអាចចំណាយមុនលើការងារសាងសង់................................................
- សូមថតចំលងសៀវភៅធានាគារ ឬលិខិតធនាគារដែលអាចបញ្ជាក់អំពីចំនួនថវិកានិងអស័យដ្ឋានទំនាក់ទំនង។

**៤. បទពិសោធន៍របស់ក្រុមហ៊ុន ឬសិប្បកម្ម**

សូមបញ្ជាក់ការងារសាងសង់ផ្គត់ផ្គង់ទឹកអោយបានយ៉ាងតិច៣ ក្នុងរយៈពេល៣ឆ្នាំ ចំពោះក្រុមហ៊ុនដែលទើបធ្វើអាជីវកម្ម។ តំលៃត្រូវបញ្ជាក់ជាដុល្លារអាមេរិច។

| ឈ្មោះគម្រោង និង ទីកន្លែង | ឈ្មោះអសយដ្ឋាន និង លេខទូរស័ព្ទម្ចាស់គម្រោង | ប្រភេទការងារ និងឆ្នាំ សាងសង់ ផលិតហើយ | តំលៃកិច្ចសន្យា |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ៥. ឧបករណ៏ ឬគ្រឿងចក្ររបស់ក្រុមហ៊ុន ឬសិប្បកម្ម

បញ្ជីរខាងក្រោម គឺជាគ្រឿងចក្ររបស់ក្រុមហ៊ុន ឬសិប្បកម្មដែលមានសំរាប់អនុវត្តការងារ។ អ្នកដេញថ្លៃផ្តល់ព័ត៌មានទាំងអស់ដែលចាំបាច់ហើយរៀបរាប់ពីរបៀបអនុវត្តការងារ។

| ល.រ | ប្រភេទគ្រឿងចក្រ ឬឧបករណ៏ | ប្រភេទការងារដែលត្រូវធ្វើ |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ៥ | | |
| ៦ | | |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |

## ៦. គុណសម្បត្តិ និងបទពិសោធន៍ការងារគ្រប់គ្រងការសាងសង់ ផលិតសំរាប់កិច្ចសន្យានេះ

(សូមភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេបនៃបុគ្គលនោះ)

| ឋានៈ | ឈ្មោះ | សញ្ញាប័ត្រ | បទពិសោធន៍ប៉ុន្មានឆ្នាំ ក្នុងជំនាញរបស់ខ្លួន | បទពិសោធសំរាប់តួនាទីនេះ |
|---|---|---|---|---|
| ប្រធានគម្រោង | | | | |
| ប្រធានវិស្វករ | | | | |
| អ្នកបច្ចេកទេស | | | | |
| អ្នកគ្រប់គ្រងការដ្ឋាន | | | | |
| | | | | |
| | | | | |

## ៧. គំរោងវិធីសាស្រ្តការងារ និងពេលវេលា

អ្នកដេញថ្លៃត្រូវភ្ជាប់ជាមួយនូវ គំនូសប្លង់ តារាងពេលវេលាដែលចាំបាច់ទៅក្នុងឯកសារដេញថ្លៃនេះ។ ព័ត៌មានខាងក្រោមត្រូវបំពេញយ៉ាងចាំបាច់បំផុតសំរាប់សាងសង់សាងសង់ឧបករណ៍លាងសម្អាតដៃដោយជើងនៅតាមសាលារៀនទាំង៤ស្រុក ៖

| ជំហាន | ពន្យល់ | រយៈពេល |
|---|---|---|
| ១ | | ........................ថ្ងៃបន្ទាប់ពីថ្ងៃចុះកិច្ចសន្យា |

| | | |
|---|---|---|
| ២ | | ..............................ថ្ងៃបន្ទាប់ពីថ្ងៃចាប់ផ្តើម |
| ៣ | | ..............................ថ្ងៃបន្ទាប់ពីថ្ងៃចាប់ផ្តើម |
| ៤ | | ..............................ថ្ងៃបន្ទាប់ពីថ្ងៃចាប់ផ្តើម |
| ៥ | | ..............................ថ្ងៃបន្ទាប់ពីថ្ងៃចាប់ផ្តើម |
| ៦ | | ..............................ថ្ងៃបន្ទាប់ពីថ្ងៃចាប់ផ្តើម |
| ៧ | | ..............................ថ្ងៃបន្ទាប់ពីថ្ងៃចាប់ផ្តើម |
| **រយៈពេលសរុបសំរាប់ការងារ** | | **..............................ថ្ងៃបន្ទាប់ពីថ្ងៃចាប់ផ្តើម** |

# ផ្នែកទី ៥ ៖
# បទដ្ឋានបច្ចេកទេស និងសេចក្តីលំអិតសម្ភារៈផលិតឧបករណ៍លាងសម្អាតដៃ ដោយជើងនៅតាមសាលារៀន

## 1- បទដ្ឋានផលិត

- ប្រើដែក វ៉ល មានទំហំខ្នាត ៥០.៨ មម គុណ ៥០.៨មម ធ្វើគ្រោង ដែកមានទំហំ ៨៨០មមគុណ ៨៨០ មម កំពស់ ១៣០០ មម។
- ដាក់ដែក វ៉ល មានទំហំខ្នាត ៥០.៨ មម គុណ ៥០.៨មមធ្វើគ្រោងទ្រ ធុងទឹក។
- ដាក់ដែកជ្រុង ២០មម គុណ ២០មម ធ្វើគ្រោងទ្រចាន ឡាបូ លាងសម្ភារដៃទំហំ៥០០មមគុណ៣៥០មម។
- ធ្វើដែកមូលសំរាប់ដាក់សាប៊ូលាងដៃ ចំនុច ២៥០មីលីលីត្រ ប្រើដែក កំរាស់៣មម ហើយដាក់ ដងសាប៊ូលាងដៃនៅខាងស្តាំដៃ ដូចនេះអ្នកប្រើប្រាស់ អាចប្រើខាងឆ្វេងដៃបាន
- ចានដែកដាក់សាប៊ូដុំ ដែលមានទំហំ១៣០គុណ១០០គុណ២០ មម ដែក ប្រភេទ ៣០៤ សំរាប់ ដាស់សាប៊ូដុំសំរាប់ប្រើប្រាស់ នៅខាងស្តាំដៃ ដូចនេះអ្នកប្រើប្រាស់ អាចប្រើខាងឆ្វេងដៃបាន។

## 2- ការត្រួតពិនិត្យមើលគុណភាពការងារ

ភាគីប្រគល់ការងារម៉ៅការនឹងពិនិត្យការងាររបស់ ភាគីទទួលការងារម៉ៅការ និងប្រាប់អំពីចំណុច ខុសឆ្គងនានា។ ភាគីប្រគល់ការងារម៉ៅការអាចបង្គាប់អោយភាគីទទួលការងារម៉ៅការការរុះរើមើលនូវការងារណាមួយដែលបានធ្វើ រួចហើយធ្វើការវាស់វែងនិងតេស្តមើលដើម្បីវាយតំលៃថាតើភាគីទទួលការងារម៉ៅការបានធ្វើតាមប្លង់ និងលក្ខណៈបច្ចេកទេសដែរ ឬអត់។

## 3- ការមិនគោរពលក្ខណៈបច្ចេកទេស និងគំនូរប្លង់នានា

- ភាគីទទួលការងារម៉ៅងការ ត្រូវអនុវត្តតាមលក្ខណៈលំអិតបច្ចេកទេសគំនូរប្លង់ និងឯកសារផ្សេងៗ ដែលមានក្នុងកិច្ចសន្យា។
- ក្នុងករណីភាគីទទួលការងារម៉ៅការមានកំហុសច្រំដែលៗ មិនគោរពកិច្ចសន្យា ភាគីប្រគល់ការងារ ម៉ៅការមានសិទ្ធបញ្ចប់កិច្ចសន្យានោះហើយធ្វើការផាកពិន័យចំពោះភាគីទទួលការងារម៉ៅការនូវតំលៃស្មើនឹង ៥% (ប្រាំភាគរយ) នៃតំលៃកិច្ចសន្យាសរុប។
- ការផាកពិន័យនេះនឹងត្រូវធ្វើឡើងក្នុងករណីមានកំហុសធ្ងន់ធ្ងរ ដូចជាការប្រែប្រួលទំហំនៃគ្រឿងបង្គុំ ឬសមាសធាតុនានានៃគំរោង។ ប្រសិនបើភាគីទទួលការងារម៉ៅការបញ្ចប់ការងារផលិត ហើយការងារ នោះមានគុណភាពអន់ជាងគុណភាពដែលតំរូវការក្នុងលក្ខណៈបច្ចេទេស តែវាមិនធ្ងន់ធ្ងររហូតដល់រុះរើ នោះភាគីទទួលការងារម៉ៅការនឹងត្រូវទទួលការផាកពិន័យនូវចំនួន មួយស្មើនឹង ២.៥ ភាគរយ លើតំលៃដែលមានក្នុងកិច្ចសន្យានៃផ្នែកការងារដែលមានបញ្ហានោះ។

## 4- ការរំលាយកិច្ចសន្យា

បើក្នុងកំឡុងពេលកិច្ចសន្យា បើភាគីប្រគល់ការងារម៉ៅការពិនិត្យឃើញថាការងារដែលធ្វើមិនត្រឹម ត្រូវតាមក្បួនខ្នាត គំនូសប្លង់ ឬក្នុងរបៀបណាមួយដែលមិនគោរពកិច្ចសន្យានិងឯកសារនានា ភាគីប្រគល់ ការងារម៉ៅការនឹងផ្តល់ដំណឹង ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ដោយបញ្ជាក់អំពីមូលហេតុនៃបញ្ហាដល់ ភាគីទទួលការងារម៉ៅការ។ ប្រសិនបើបញ្ហាដែលបានលើកឡើងមិនបានដោះស្រាយក្នុងរយៈពេល ១៥ ថ្ងៃទេនោះភាគីប្រគល់ការងារម៉ៅការមានសិទ្ធិបញ្ចប់កិច្ចសន្យាដោយគ្មានការបើកប្រាក់តទៅទៀតឡើយ។

**5- ប្រតិទិនសំរាប់ធ្វើការងារសាងសង់**

ប្រតិទិនសំរាប់ធ្វើការងារសាងសង់នឹងផ្អែកទៅលើការអនុវត្តការងារ ៦ថ្ងៃក្នុងមួយសប្តាហ៍។

**6- រយៈពេលដើម្បីបញ្ចប់ការងារកិច្ចសន្យា**

ភាគីទទួលការងារម៉ៅការត្រូវចាប់ផ្តើមអនុវត្តការងាររបស់ខ្លួនតាមការបរិច្ឆេទក្នុងកិច្ចសន្យា ដោយមិន បណ្តោយឱ្យមានការពន្យាពេលណាមួយធៀបទៅនឹងផែនការ។ ប្រសិនបើគ្មានការស្នើរសុំពន្យាពេលជា លាយលក្ខ័អក្សររបស់ភាគីទទួលការងារម៉ៅការ និងគ្មានការអនុម័ត្តពីភាគីប្រគល់ការងារម៉ៅការទេនោះ រយៈពេលសាងសង់មិនត្រូវលើសរយៈពេលដែលបានចែងក្នុងកិច្ចសន្យាជាដាច់ខាត។ ពេលក្នុងកាលៈទេសៈដែលភាគីទទួលការងារម៉ៅការមិនអាចគ្រប់គ្រងបាន ត្រូវដាក់សុំពន្យាពេល ជូនភាគីប្រគល់ការងារម៉ៅការអោយបានរួសរាន់ជាទីបំផុតមិនអោយលើសពីប្រាំពីរថ្ងៃ បន្ទាប់ពីភាគីទទួលការងារម៉ៅការបាន ជួបប្រទះការយឺតយ៉ាវនេះ។

**7- ការបញ្ចប់ការងារជាស្ថាពរ**

ការងារក្នុងកិច្ចសន្យាដែលអាចចាត់ទុកថាចប់ជាស្ថាពរនោះគឺនៅពេលដែលការងារទាំងនោះបាន បញ្ចប់ដោយត្រឹមត្រូវនិងមានការពេញចិត្តពីសំណាក់ភាគីប្រគល់ការងារម៉ៅការតាមរយៈការធ្វើតេស្ត ត្រួតពិនិត្យជាចុងក្រោយ។

**8- ការពិន័យចំពោះការពន្យាពេលបញ្ចប់ការងារ**

ចំពោះការពន្យាពេលក្នុងការបញ្ចប់គំរោងដោយគ្មានការព្រមព្រៀងពីភាគីប្រគល់ការងារម៉ៅការទេនោះ ភាគីទទួលការងារម៉ៅការនឹងត្រូវពិន័យជាទឹកប្រាក់នូវអាត្រា ០.២៥ ភាគរយនៃតំលៃកិច្ចសន្យា សរុបក្នុងមួយថ្ងៃ អត្រាផាកពិន័យនេះនឹងកើនឡើងរហូតដល់ ១០ ភាគរយ នៃតំលៃកិច្ចសន្យាសរុបក្នុងមួយថ្ងៃបើការយឺតយ៉ាវពន្យាពេលលើសពី ០១ខែ។

**9- រយៈពេលថែរក្សា និងអសុក្រិតភាព**

ភាគីទទួលការងារម៉ៅការធានាគុណភាពគំរោងរយៈពេល ០៦ ខែ បន្ទាប់ពីបញ្ចប់ការអនុវត្តការងារក្នុងកិច្ចសន្យាបានបញ្ចប់ការងារជាស្ថាពរ។ ភាគីទទួលការងារម៉ៅត្រូវការធានាជួសជុលលើការខូចខាតទាំងឡាយដែលបណ្តាលមកពីកំហុសក្នុងពេលផលិតហើយភាគីទទួលការងារម៉ៅការ ជាអ្នកទទួលខុសត្រូវក្នុងការចំណាយ។ ប្រសិនបើភាគីទទួលការងារម៉ៅការមិនបានធ្វើការជួសជុល កែលំអរដូចតាមការណែនាំ ក្នុងរយៈពេល ១៥ ថ្ងៃ ទេនោះ ភាគីប្រគល់ការងារម៉ៅការនឹងរកអ្នកដទៃដើម្បី ធ្វើការជួសជុល ហើយការចំណាយរាប់កិច្ចការនេះ នឹងត្រូវកាត់ចេញពីប្រាក់ដែលត្រូវទូទាត់ចុងក្រោយ របស់ភាគីទទួលការងារម៉ៅការ។

**10- ដំណើការនៃការទូទាត់ការងារក្នុងកិច្ចសន្យា**

ភាគគីប្រគល់ការងារម៉ៅការទាមទារអោយភាគគីទទួលការងារម៉ៅការអនុវត្ត និងបញ្ចប់កិច្ចសន្យា សំរាប់អត្រាតំលៃដែលបានកំណត់ និងព្រមព្រៀងគ្នារួចហើយដូចមានចែងក្នុងបញ្ជីរប៉ាន់ស្មានតំលៃ។ តំនើរការទូទាត់នេះនឹងធ្វើឡើងដោយផ្អែកលើកិច្ចព្រមព្រៀងផ្តល់សេវារវាងភាគគីប្រគល់ការងារម៉ៅការ និងភាគីទទួលការងារម៉ៅការ។

**11- ដំណាក់កាលសំខាន់ៗនៃការចុះត្រួតពិនិត្យការដ្ឋាន**

អង្គការភ្លែនអន្តរជាតិកម្ពុជានឹងត្រួតពិនិត្យសំខាន់ៗចំនួន ០៩ ដំណាក់កាលដែលធ្វើឡើង ដោយអ្នកសំរបសំរួលបច្ចេកទេស ឬ បុគ្គលិករបស់ភាគីប្រគល់ការងារម៉ៅការ។

**12- ការបង់ពន្ធនាំចូល**

រាល់សម្ភារៈបរិក្ខារទាំងអស់ ដែលយកមកប្រើប្រាស់ក្នុងការសាងសង់ត្រូវតែមានបង់ពន្ធនាំចូល តាមច្បាប់របស់រដ្ឋាភិបាលកម្ពុជា។

## 13- សម្ភារដែលត្រូវយកមកផលិត

| | | |
|---|---|---|
|  | **១-ឈ្មោះផលិតផល** | ធុងចំណុះ៥០០លីត្រ |
| | កូត | អាយុកាល ៥ឆ្នាំ |
| | ទំហំ | ៨៨០មម គុណ ៩៥០ គុណ៤០០មម |
| | មុខកាត់ | |
| | ពណ៌ | ខៀវ |
| | គុណភាព | ថ្មី ល្អ |
|  | **២-ឈ្មោះផលិតផល** | ឡាបូលាងដៃ |
| | កូត | អ៊ីណុកផលិតថៃ |
| | ទំហំ | ៥២០មមគុណ៣៦០មម |
| | មុខកាត់ | |
| | ពណ៌ | ស |
| | គុណភាព | ថ្មី ល្អ |
|  | **៣-ឈ្មោះផលិតផល** | ទុយោបង្ហូរទឹកកខ្វក់ |
| | កូត | |
| | ទំហំ | ៤៩មម គុណ ១៧៥០មម |
| | មុខកាត់ | |
| | ពណ៌ | ស |
| | គុណភាព | ថ្មី ល្អ |
|  | **៤-ឈ្មោះផលិតផល** | ដែក វ៉េ |
| | កូត | SD 290 |
| | ទំហំ | ២៥.៤មមគុណ២៥.៤មម |
| | មុខកាត់ | |
| | ពណ៌ | ស |
| | គុណភាព | ថ្មី ល្អ |

| | | |
|---|---|---|
|  | **៥-ឈ្មោះផលិតផល** | ដែកជ្រុង |
| | កូត | |
| | ទំហំ | ២០មម គុណ ២០មម |
| | កំរាស់ | ១.២លី |
| | ពណ៌ | ស |
| | គុណភាព | ថ្មី ល្អ |
|  | **៦-ឈ្មោះផលិតផល** | ដែកថ្នាំងអំពៅ |
| | កូត | SD 390 |
| | ទំហំ | ១២មម |
| | មុខកាត់ | |
| | ពណ៌ | មិនច្រេះ |
| | គុណភាព | ថ្មី ល្អ |
|  | **៧-ឈ្មោះផលិតផល** | ក្បាលរ៉ូប៊ីណេ |
| | សម្ភារៈ | ដែកអ៊ីណុក ផលិតនៅថៃ |
| | ផ្ទៃ | រលោង |
| | ប្រដាក់បិទបើក | លើក |
| | ពណ៌ | ស |
| | គុណភាព | ថ្មី ល្អ |
|  | **៨-ឈ្មោះផលិតផល** | រឺស័រ |
| | ប្រភេទ | AWY_DL ២-១0 |
| | ទំហំដែរុំ | 0.២៥ |
| | ទំហំកំលាំងញូវតុន | ១.៨៦ |
| | ទំហំកំលាំងយឺតដំបូងញូវតុន | 0.៣៤ |
| | គុណភាព | ថ្មី ល្អ |
|  | **៩-ឈ្មោះផលិតផល** | ទុយោ PVC |
| | ទំហំ | ៣៤ មម |
| | កំរាស់ | ៨.៥ |
| | កូត | |
| | ពណ៌ | ខៀវ |
| | គុណភាព | ថ្មី ល្អ |

| | | |
|---|---|---|
|  | **១០-ឈ្មោះផលិតផល** | ថ្នាំលាបច្រេះ |
| | ចំណុះ | (0.5លីត្រ) |
| | កំរាស់ | |
| | កូត | |
| | ពណ៌ | ខៀវ |
| | គុណភាព | ថ្មី ល្អ |
|  | **១១-ឈ្មោះផលិតផល** | តេជ័រ |
| | ទំហំ | ៣៤ មម |
| | កំរាស់ | ៨.៥ |
| | កូត | ថៃ |
| | ពណ៌ | ខៀវ |
| | គុណភាព | ថ្មី ល្អ |
|  | **១២-ឈ្មោះផលិតផល** | ចានដែកដាក់សាប៊ូដុំ |
| | ទំហំ | ១៣០គុណ១០០គុណ២០ មម |
| | កំរាស់ | ២០មម |
| | កូត | ដែក ប្រភេទ ៣០៤ |
| | ពណ៌ | ស |
| | គុណភាព | ថ្មី ល្អ |

# ផ្នែកទី ៦៖
# បញ្ជីប៉ាន់តម្លៃសាងសង់ឧបករណ៍លាងសម្អាតដៃដោយជើងនៅតាមសាលារៀន

| ល.រ | បរិយាយ | ឯកតា | ចំនួន | តម្លៃ ($) | សរុប ($) |
|---|---|---|---|---|---|
| 1 | គ្រោង | | | | |
| 1.1 | ដែកជ្រុង 20មម 1.2លី_ដែកស | ម៉ែត្រ | 6.5 | | |
| 1.2 | ដែករ៉េ 30មម SD290- លេខ១ របស់ខ្មែរ | ម៉ែត្រ | 16 | | |
| 1.3 | ដែកថ្នាំងអំពៅ 10លី_សម្រាប់ជាន់ | ម៉ែត្រ | 6 | | |
| 2 | សម្ភារៈទុយោទឹក | | | | |
| 2.1 | ទុយោជ័រ 34មម កំរ៉ាស់ 8.5 (របស់ថៃលេខ១) | ដើម | 1 | | |
| 2.2 | តេជ័រ 34មម (របស់ថៃ) | តេ | 1 | | |
| 2.3 | ទុយោជ័រ 49មម បង្ហូរទឹកកខ្វក់ចេញ | ដើម | 2 | | |
| 3 | សំសម្ភារៈស្តុបទឹក និងឡាបូ | | | | |
| 3.1 | ស៊ីទែនទឹកជ័រចំណុះ ៥០០លីត្រ (អាយុកាល ៥ឆ្នាំ) | ធុង | 1 | | |
| 3.2 | ក្បាលរ៉ូប៊ីណេលាងដៃ (អ៊ីណុកផលិតនៅថៃ) | ឈុត | 2 | | |
| 3.3 | ឡាបូលាងដៃ (360x520មម) (អ៊ីណុកផលិតនៅថៃ) | ឈុត | 2 | | |
| 4 | ថ្នាំលាបច្រេះ និងពណ៌ខៀវ (0.5លីត្រ) | | | | |
| 4.1 | ថ្នាំលាបច្រេះ | លីត្រ | 0.5 | | |
| 4.2 | ពណ៌ខៀវ (0.5លីត្រ) | លីត្រ | 0.5 | | |
| 5 | ផ្លាកម្ចាស់ជំនួយ | | | | |
| 5.1 | ស្លាកកម្ចាស់ជំនួយ | ឈុត | 1 | | |
| 5 | ថ្លៃកំលាំងពលកម្ម | | | | |
| 5.1 | ថ្លៃកំលាំងពលកម្ម | ឈុត | 1 | | |
| A | តម្លៃសរុបរួម | | | | |
| B1 | ប្រាក់ពន្ធ 10% នៃតម្លៃសរុប (បើក្រុមហ៊ុនមាន VAT) | | | | |
| B2 | ឬ ប្រាក់ពន្ធ 15% នៃតម្លៃកំលាំងពលកម្ម/សេវាកម្ម (បើក្រុមហ៊ុនគ្មាន VAT) | | | | |
| C | តម្លៃដេញថ្លៃសរុប (A+B1) ឬ (A+B2) | | | | |

ចំណាំ៖ តម្លៃឧបករណ៍លាងសម្អាតដៃដោយជាន់ជើង ដោយគិតក្នុងមួយគ្រឿង បូករួមបញ្ចូលការដឹកជញ្ជូន និងតំឡើងដល់ទីតាំងគោលដៅខាងលើ។

**ខ្ញុំបាទ/នាងខ្ញុំសូមបញ្ជាក់ថា ៖**

តម្លៃដេញថ្លៃសរុបរួមទាំងអស់ចំនួន........................................................................................................ដុល្លារអាមេរិក។

តម្លៃដេញថ្លៃសរុបក្រោយពីគណៈកម្មការពិនិត្យ និងកែតម្រូវគឺ ....................................................................ដុល្លារអាមេរិក។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ .......................................................................................................................................

ជាប្រធាន/តំណាងក្រុមហ៊ុនផ្គត់ផ្គង់ឈ្មោះ.......................................................................................................

សូមឯកភាពរក្សាតម្លៃដេញថ្លៃក្រោយពីគណៈកម្មការពិនិត្យ និង/កែតម្រូវ សម្រាប់រយៈពេល ៦០ថ្ងៃ។

ខ្ញុំបាទ/នាងខ្ញុំសូមឯកភាពរក្សាទទួលយកបរិមាណ បញ្ជីរាយឈ្មោះការងារ សម្ភារៈសំណង់ និងគុណភាព នៅក្នុងតារាងតម្លៃដាក់ដេញថ្លៃខាងលើនេះថាត្រឹមត្រូវតាមប្លង់ និងធ្វើការសាងសង់រហូតបញ្ចប់គម្រោង(ដោយមានការយល់ព្រមពីគណៈកម្មការពិនិត្យ)។

**បញ្ជាក់ ៖** អ្នកដេញថ្លៃត្រូវផ្ទៀងផ្ទាត់បរិមាណ បញ្ជីរាយឈ្មោះការងារ សម្ភារៈសំណង់ និងគុណភាព នៅក្នុងតារាងប៉ាន់ស្មានតម្លៃ។

ធ្វើនៅថ្ងៃទី............. ខែ............. ឆ្នាំ.............

ហត្ថលេខា ត្រាអង្គភាព និង ឈ្មោះ

# ផ្នែកទី៧ ៖
# គំនូសប្លង់

(សូមមើលលើឯកសារគំនូសប្លង់លំអិត A3)